**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ : ២៥៩២ មស.សជណា

**សេចក្តីជូនដំណឹង**

**យោង ៖** - លិខិតលេខ៨៤៤ លស.អរហ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១ របស់ក្រសួងទេសចរណ៍
- យោងតាមការចាំបាច់ និងសំណូមពរការងារ។

គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងមុខងារសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សូមជម្រាបជូនដំណឹងដល់សិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិលទាំងអស់ ឱ្យបានជ្រាបថា យោងតាមសំណើសុំបញ្ចូលការប្រឡងជ្រើសរើសក្របខ័ណ្ឌថ្មី ឆ្នាំ២០២១ របស់ក្រសួងទេសចរណ៍ ចូលក្នុងការប្រឡងជ្រើសរើសក្រសួង ស្ថាប័នទាំង៧ ដែលរៀបចំឡើងដោយក្រសួងមុខងារសាធារណៈ។ ក្រសួងមុខងារសាធារណៈសម្រេចបញ្ចូលការប្រឡងជ្រើសរើសនិស្សិត និងមន្ត្រីរាជការ ចំនួន **១៤កន្លែង** របស់ក្រសួងទេសចរណ៍ ទៅក្នុងការប្រឡងជ្រើសរើសក្របខ័ណ្ឌ ក្រសួង ស្ថាប័នទាំង៧។

ចំពោះបញ្ជីឈ្មោះបេក្ខជន គណៈកម្មការរៀបចំការប្រឡងនឹងធ្វើការបិទផ្សាយនៅពេលបញ្ឈប់ការទទួលពាក្យក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា។

កាលបរិច្ឆេទប្រឡង និងមណ្ឌលប្រឡង គណៈកម្មការរៀបចំការប្រឡងនឹងជូនដំណឹងពេលក្រោយទៀត។

សេចក្តីដូចបានជម្រាបជូនខាងលើសូម សិស្ស និស្សិត និងមន្ត្រីរាជការ ដែលបានដាក់ពាក្យប្រឡងចូលក្របខ័ណ្ឌក្រសួង ស្ថាប័ន ខាងលើជ្រាបជាព័ត៌មាន៕

ថ្ងៃព្រហស្បតិ៍ ៥រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១
**រដ្ឋលេខាធិការ និងជា**
**ប្រធានគណៈកម្មការរៀបចំការប្រឡង**

**អែម ប៊ុនថុល**

ផ្លូវវិថីអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh